# THE CONJUNCTION

407. *Since*, as a Conjunction, means—

407. *Since* ជា Conjunction មានន័យថា —

(1) From and after the time when; as,

(1) ចាប់តាំងពី/ពីនិងបន្ទាប់ពីពេលដែល ដូចជា

Since + | noun (Prep) / clause (Conj) | = ចាប់តាំងពី

Since (adv) = ចាប់តាំងពីពេលនោះមក

Present Perfect (Mail Clause) + since + past sumple (Subclause)

I have been in such a pickle <u>*since*</u> I saw you <u>*last*</u>.

OR I have been in such a pickle <u>*since*</u> I <u>*last*</u> saw you.

ខ្ញុំស្ថិតក្នុងស្ថានភាពលំបាកបែបហ្នឹងចាប់តាំងពីខ្ញុំបានជួបអ្នកលើកចុងក្រោយមក ។

to be in a pickle = ស្ថិតក្នុងស្ថានភាពពិបាក

Many things have happened <u>*since*</u> I left school.

អ្វីៗជាច្រើនបានកើតឡើងចាប់តាំងពីខ្ញុំឈប់រៀនមក ។

I have never seen him <u>*since*</u> that unfortunate event happened.

ខ្ញុំមិនដែលបានឃើញគាត់ទេចាប់តាំងពីហេតុការណ៍អកុសលនោះកើតឡើងមក ។

unfortunate = អកុសល

unfortunate event = ហេតុការណ៍អកុសល

Note.—*Since*, when used as a Conjunction in this sense, should be preceeded by a verb in the *present perfect tense*, and followed by a verb in the *simple past tense*.

សំគាល់--*Since* នៅពេលដែលប្រើជា Conjunction នៅក្នុងន័យនោះគួរតែនាំមុខដោយ Verb នៅក្នុងកាល Present Perfect ហើយបន្តតាមក្រោយដោយ Verb នៅក្នុងកាល Past Simple ។

to preceed = នាំមុខដោយ

Since (S) , when ~~it~~ (S) ~~is~~ (V) used (PP) as a Conjunction in this sense , should be (V) .....

⇨ Since, when used (PP) as a Conjunction in this sense, should be ....

នៅពេលដែល Since ត្រូវគេប្រើជា Conjunction ក្នុងន័យនេះ Since គួរតែ.....

*** Adverb of time នាំមុខដោយ Conjunction *when* ក៏អាចបំពេញបានដែរនៅពេលដែល Subjet ដូចគ្នា ។ នៅពេលយើងបំពេញគឺលុប Subject ហើយបើ Verb ទំរង់ Passive មាន to be នៅក្នុងនោះ to be ត្រូវលុបចោល ។ យើងអាចយក Subclause នោះមកដាក់ដើមឃ្លាបាន ។

When used as a Conjunction in this sense (Subclause) , Since should be (Main Clause) .....

www.salarean.com

***ពេលខ្លះនៅក្នុង Instruction, ក្នុងសៀវភៅណែនាំគេអាចបំព្រួញបានមិនចាំបាច់មាន Subject ទាក់ទងគ្នាទេ ។

When in doubt, ask me. (ទំរង់ Imperative)

When ~~you are~~ in doubt, ask me.

I will help you whenever possible. ខ្ញុំនឹងជួយអ្នកពេលណាក៏ដោយឱ្យតែអាចធ្វើបាន ។

I will help you whenever ~~it is~~ possible.

(2) Seeing that, inasmuch as; as

(2) ដោយសារ, ដោយយល់ឃើញថា/ដោយហេតុថា ដូចជា

Seeing that = ដោយសារ, ដោយយល់ឃើញថា (Adv of cause)

inasmuch as = ដោយសារ, ត្រង់ថា (Adv of cause)

Since you wish it , it shall be done .

ដោយហេតុថាអ្នកប្រាថ្នាចង់បានថាទៅហើយនោះវានឹងត្រូវគេធ្វើឡើង ។

Since you will not work , you shall not eat .

ដោយហេតុថាអ្នកនឹងមិនធ្វើការអញ្ចឹងអ្នកនឹងមិនហូបដែរ ។

Since that is the case , I shall excuse you.

Adv of cause/reason — V

*Adverb of cause/reason បំពេញន័យឱ្យ Verb excuse ។

to be the case = to be true = ជាការពិត

to excuse = អភ័យទោស

*យើងអាចសួរថាហេតុអ្វីបានខ្ញុំអភ័យទោសឱ្យអ្នក ដោយសារនេះជាការពិតទៅហើយ ។

*បំពេញន័យឱ្យ Verb ប្រាប់ពីមូលហេតុដែលថាតើហេតុអ្វីបានជាអភ័យទោស ។

*Subclause គឺជាផ្នែកមួយរបស់ Main clause ។ Subclause ជា Adverb មួយបំពេញន័យឱ្យពាក្យអ្វី១នៅក្នុង Main clause ។

408. *Or* is used—

408. *Or* ត្រូវបានគេប្រើ-

(1) To introduce an alternative, as

(1) ដើម្បីផ្ដើមជំរើសមួយ/នាំមុខជំរើសមួយ ដូចជា

Your purse *or* your life. យកកាបូបឬយកជីវិត ។

You must work *or* starve. អ្នកត្រូវតែធ្វើការឬត្រូវអត់អាហារ ។

to strave (vi) = អត់អាហារ

(vt) = បង្អត់អាហារ

www.salarean.com

You may take this work *or* that one.

អ្នកអាចយកសៀវភៅនេះឬយកអាមួយនោះ ។

Note.—There may be several alternatives each joined to the preceeding one (=alternative) by *or*, presenting a choice between any two in the series; as,

សំគាល់-អាចមានជម្រើសច្រើនដោយជម្រើសនីមួយៗត្រូវភ្ជាប់ទៅនិងជម្រើសខាងមុខដោយពាក្យ or ដោយបង្ហាញពីជម្រើសមួយរវាងពាក្យពីរណាក៏ដោយក្នុងពាក្យមួយឈុត ដូចជា

He may study law or (1) medicine or (2) engineering or (3) he may enter into trade.

អ្នកអាចរៀនច្បាប់ឬរៀនពេទ្យឬរៀនវិស្វកម្ម ឬអ្នកអាចចូលរកស៊ីអាជីវកម្ម ។

ពាក្យ or ទីមួយ ភ្ជាប់ពាក្យ medicine និងពាក្យ law ។

ពាក្យ or ទីពីរ ភ្ជាប់ពាក្យ medicine និងពាក្យ engineering ។

ពាក្យ or ទិបី ភ្ជាប់ឃ្លាខាងក្រោមទាំងអស់និងឃ្លាខាងមុខទាំងអស់ ។

(2) to introduce an althernative name or synonym; as,

(2) ដើម្បីផ្ដើមឈ្មោះឬ Synonym ដែលជាជម្រើស ដូចជា

The violin *or* fiddle has become the leading intrument of the modern orchestra.

Violin ឬ fiddle បានក្លាយទៅជាឧបករណ៍សំខាន់ជាងគេនៅក្នុងវង់ភ្លេងសម័យ ។

...... $ 1 billion, or 10% ...... (គេហៅថាជម្រើសដែលមានន័យស្មើគ្នា)

...... ប្រាក់១ពាន់លានដុល្លារ *ស្មើនឹង 10% នៃ* ......

...... ប្រាក់១ពាន់លានដុល្លារ *ស្មើនឹង 10% នៃ* ......

leading = នាំមុខគេ, សំខាន់ជាងគេ

instrument = ឧបករណ៍

orshestra = វង់តន្ត្រីសម័យ

(3) To mean *otherwise*; as,

(3) មានន័យថា បើពុំនោះទេ/បើមិនអញ្ចឹងទេ

Or/or else/ else = otherwise = បើពុំនោះទេ / បើមិនអញ្ចឹងទេ

We must hasten *or* might will overtake us.

យើងត្រូវតែប្រញាប់បើមិនអញ្ចឹងទេយប់ងងឹតមុនយើងហើយ ។

(ឧ. មុនយើងធ្វើកិច្ចការអ្វី១, មុនទៅដល់គោលដៅ)

hasten = ប្រញាប់ប្រញាល់

overtake = វ៉ា (ឧ. ជិះកង់ , ជិះវ៉ាឡាន)

(4) As nearly equivalent to *and*; as,

(4) *Or* ត្រូវបានប្រើស្ទើរតែជាសមមូលរបស់ពាក្យ *and* ដូចជា

The troops were not strength *or* courage, but they were badly fed.

កងទ័ពមិនមែនគ្មានកំលាំងឬសេចក្ដីក្លាហាននោះទេប៉ុន្តែពួកគេត្រូវបានគេឱ្យចំណីអាហារមិនគ្រប់គ្រាន់ ។

www.salarean.com

be wanting in sth = ខ្វះឬអត់មានអ្វី១ (ដែលជាចាំបាច់)

strength = កំលាំង

badly fed = ផ្តល់ចំណីមិនគ្រប់គ្រាន់

409. *If* is used to mean—

409. *If* ត្រូវប្រើ

If (adv of condition) = បើ

If (noun clause) = ថាតើ

(1) On the condition that or supposition that; as,

(1) បើ/ក្នុងលក្ខខ័ណ្ឌដែល

*If* he is there, I shall see him. ប្រសិនបើគាត់នៅទីនោះខ្ញុំនឹងបានជួបគាត់ ។

*If* that is so, I am content. បើវាដូច្នោះមែននោះខ្ញុំសប្បាយចិត្តហើយ ។

(2) Admitting that, as,

(3) បើ/ទោះបីជា ដូចជា

Admitting that = although = បើ/ទោះបីជា

*If* I am blunt, I am at lest honest.

OR I am at lest honest *if* I am blunt.

បើ/ទោះបីជា ខ្ញុំនិយាយចំៗក៏ដោយក៏យ៉ាងហោចណាស់ខ្ញុំជាមនុស្សស្មោះត្រង់ដែរ ។

Blunt (adj) = ដែលនិយាយចំៗ

To put it bluntly (Adv of sentence), ....... = និយាយឱ្យចំទៅ......

*If* I am poor, *yet* I am honest.

ទោះបីជាខ្ញុំក្រក៏ដោយក៏ខ្ញុំជាមនុស្សស្មោះត្រង់ដែរ ។

Yet = ទោះបីជា (មិនប្រើជាទូទៅទេ)

Tough/If....yet (ការប្រើមិនទូទៅទេ)

(3) Whether; as,

(3) ថាតើ (Noun Clause) ដូចជា

I asked him *if* he would help me.

ខ្ញុំសួរគាត់ថាតើគាត់នឹងជួយខ្ញុំដែរឬអត់ ។

Direct: "Will you help me?"

Indirect: A | asked / wanted to know / wondered (Verb) | if B would help A (Noun Clause) .

I wonder *if* he will come.

(4) Whenever; as,

(4) When/whenever = នៅពេលដែល/ពេលណាក៏ដោយ/បើ ដូចជា

www.salarean.com

*If* I feel any doubt I inquire.

ប្រសិនបើខ្ញុំមានការសង្ស័យអ្វី ខ្ញុំនឹងសួរ ។

to feel any doubt = មានចំងល់ , មានការសង្ស័យ

to inqurie = សួរ

*If* is also used to express wish or surprise; as,

*If* នេះក៏ត្រូវប្រើដើម្បីបញ្ជាក់ពីបំណងឬការភ្ញាក់ផ្អើល ដូចជា

If I only know! (Second Condition)

| | | | | |
|---|---|---|---|---|
| Only if | I | knew! (Present) | ស្តាយណាស់ | ដែលខ្ញុំអត់ដឹង! |
| If only ↓ ប្រើទូទៅ | | had known! (Past) | | បើខ្ញុំដឹងទៅមានអី! |

410. *That*, as a Conjunction, retains much of its force as a Demonstrative Pronoun. Thus the sentence '*I am told that you are miserable'* may be transposed into '*You are miserable: I am told that.'*

410. That ជា Conjunction រក្សាកំលាំងរបស់វាភាគច្រើនជា Demonstrative Pronoun (ចង់មានន័យថារបស់វាលំអៀងទៅរក Demonstrative Pronoun ច្រើនជាង that ដែលមានន័យថានោះ) ។ ដូច្នេះឃ្លាដែលថា '*I am told that you are miserable*' អាចផ្លាស់ប្តូរមកជា 'You are miserable: I am told that.' ។

You are miserable: I am told that.

អ្នកឯងមិនសប្បាយចិត្តៈ ខ្ញុំត្រូវគេប្រាប់ថាអញ្ចឹង ។

transpose = ផ្លាស់ប្តូរ

retain = រក្សា

miserable = unhappy = អត់សប្បាយចិត្ត

I am told that he is miserable.

The people here are kind.

The people living here are kind.

to tell sb that-clause

Sb is told that-clause = នរណាម្នាក់ត្រូវបានគេប្រាប់ថា......

I am told that he is miserable.

ខ្ញុំត្រូវបានគេប្រាប់ថា គាត់អត់សប្បាយចិត្ត ។

*That* is used—

*That* ត្រូវបានគេប្រើ –

(1) To express a Reason or Cause, and is equivalent to *because, for that, in that;* as,

(1) ដើម្បីបញ្ជាក់ពីហេតុផលហើយជាសមមូលរបស់ពាក្យ because (=ដោយសារ), for that (=ដោយសារ), in that (=ដោយសារ/ត្រង់ថា) ដូចជា

[ ក្នុងភាសាអង់គ្លេសសម័យបច្ចុប្បន្ន ន័យនេះកម្រប្រើណាស់ ]

www.salarean.com

Not *that* I loved Caesar less, but *that* I loved Rome more.

មិនមែនថា ខ្ញុំស្រលាញ់ Caesar តិចនោះទេ តែមកពីខ្ញុំស្រលាញ់ Rome ច្រើន ។

Not that = មិនមែនដោយសារ/មិនមែនថា/មិនមែនមកពីថា/មិនមែនពីព្រោះ

that = ពីព្រោះ

He was annoyed *that* he was contradicted.

គាត់ខឹងមួម៉ៅដោយសារតែគាត់ត្រូវគេនិយាយជំទាស់ ។

annoye = ខឹង, មួម៉ៅ

to contradict = និយាយផ្ទុយ, និយាយជំទាស់

(2) To express a Purpose, and is equivalent to *in order that*; as,

(2) That ប្រើសំរាប់បញ្ជាក់ពីគោលបំណងហើយជាសមមូលរបស់ពាក្យ in order that ដូចជា

in order that = so that = ដើម្បី [ បច្ចុប្បន្នលែងប្រើ ]

We sow *that* we may reap.

បើសាបព្រោះដើម្បីយើងអាចប្រមូលផល ។

to sow = សាបព្រោះ

to reap = ប្រមូលផល , ទទួលផល

He kept quiet *that* the dispute might cease.

គាត់នៅស្ងៀមដើម្បីឱ្យជម្លោះហ្នឹងលែងមាន ។

keep quiet = រក្សាភាពស្ងៀមស្ងាត់

dispute = ជម្លោះ

to cease = ឈប់, លែងមាន = to stop

(Note: Today *that* is rarely used for reason or pirpose.)

(ចំណាំ: សព្វថ្ងៃនេះពាក្យ that គេកម្រយកមកប្រើដើម្បីបញ្ជាក់ពីហេតុផលនិងគោលបំណងណាស់ ។)

(3) To express a Consequence, Result, or Effect; as,

(3) ប្រើសំរាប់បញ្ជាក់ពីលទ្ធផល ដូចជា

Consequence = លទ្ធផល, ផលវិបាក

Result = លទ្ធផល

Effect = លទ្ធផល

…… so + adj / adv + that - clause (Adv of result) — ADJ/ADV Phrase

................................. រហូតដល់/រហូតទាល់តែ

I (S) am (V) tired (C (Obj)) .

www.salarean.com

I (S) am (V) so tired (ADJ) + that I cannot go on (ADV) [ADJ Phrase (C)] . ត្រឡប់ Subject

S + V + so + adj/adv + that-clause

So + adj/adv + V + S

I am *so tired* that I cannot go on.

e.g. *So tired* am (V) I (S) that I cannot go on.

ពេលត្រឡប់ so tired មកដើមឃ្លាត្រូវត្រឡប់ Subject ។

He (S) bled (Vi) so profusely (ADV) that he died [ADV Phrase] .

*So profusely* did (V) he (S) bleed that he died.

*** Verb ធម្មតាមិនអាចត្រឡប់បានទេត្រូវប្រើ Verb ជំនួយ do ។

He (S) was (S) so tired *that* he could scarcely stand.

គាត់អស់កំលាំងពេករហូតដល់គាត់ស្ទើរតែមិនអាចឈរបាន ។

Scarcely = hardly = ស្ទើរតែមិន

*So tired* was (V) he (S) that he could scarely stand.

He runs *so fast that* no one can catch up. គាត់រត់លឿនពេករហូតដល់គ្មាននរណាតាមទាន់ ។

*So fast* does (V) he (S) that no one can catch up.

to catch uo with sb = តាមទាន់ sb

*** Adverb Clause សំគាល់ដោយសារ Conjunction ។

411. *Than* as a Conjunction, follows adjectives and adverbs in the comparative degree; as,

411. *Than* ជា Conjunction វាឈរពីក្រោយ Adjective និង Adverb នៅក្នុងទំរង់ Comparative degree ដូចជា

Than (conj.) + Clause

Than (prep.) + Noun / Pronoun

www.salarean.com

...... comparative + than + clause / noun/pronoun

Main Clause — Adv of comparision, Subcluase of comparison

He (S) is (V) tall (C (Adj)) .

taller (ADJ) + than me (Adv of comparison) — ADJ Phrase .

He (S) run (Vi) fast (ADV) .

faster *than* I (~~do~~).

faster (ADV) + than me (Adv of comparison) — ADV Phrase .

He runs (Vi) faster than me (Adv Phrase) .

Wisdom is good.

Wisdom is better (Adj) *than rubies (are)* (Adj Phrase) .

rubies (n) = ត្បូងទទឹម

Wisdom is *better* than (Conj) rubies *are* (Adv of comparison) .

Wisdom is *better* than (Prep) rubies (Adv of comparison) .

I see you oftener (Adv) than (I see) him (Adv of comparison) — Adv Phrase modyfies "see" .

often (adv of frequency) = ញឹកញាប់

I am better (ADV) acquainted (ADJ) with the country *than* you are.

www.salarean.com

to be aquainted with = ស្គាល់

I am aquainted (ADV) with it. ខ្ញុំស្គាល់វា ។

I am well (ADV) aquainted (ADJ) with it. ខ្ញុំស្គាល់វាច្បាស់ ។

I am better (ADV) aquainted (ADJ) with it. ខ្ញុំស្គាល់វាច្បាស់ជាង ។

I would rather suffer (V) *than* that (N) you should want. [ កម្រប្រើ ]

ខ្ញុំសុខចិត្តទទួលរងនូវ *ការលំបាក/ទុក្ខ* ជាជាងអ្វីដែលអ្នកគួរត្រូវការចង់ដឹង ។

Would rather *do sth* than *do sth* [ សំណង់ឃ្លាទូទៅ ]

= ចូលចិត្ត/សុខចិត្តធ្វើអ្វី១ជាជាងធ្វើអ្វី១

(do sth និង do sth បើ Verb ខាងមុខនិង Verb ខាងក្រោយដូចគ្នាគេអាចលុបចោល ។

e.g. I would rather drink coffee than (~~*drink*~~) tea.

ខ្ញុំសុខចិត្តផឹកកាហ្វេវិញគ្រាន់បើជាងផឹកតែ ។

I would rather live in Phnom Penh than (~~*live*~~) in the country.

ខ្ញុំសុខចិត្តរស់នៅភ្នំពេញវិញជាជាងរស់នៅជនបទ ។

I would rather *die* than *eat* Prahok. (=Fommented fish)

412. *Lest* is used as a Subbordinating Conjunction expressing a negative purpose, and is equivalent to 'in order that.....not', 'for fear that'; as,

412. *Lest* ត្រូវបានគេប្រើជា Subbordinating Conjunction បញ្ជាក់អំពីគោលបំណងបដិសេធ ហើយជាសមមូលទៅនិងពាក្យ "in order that.....not" ឬក៏មានន័យថា "for fear that" ដូចជា

Lest = ដើម្បីកុំឱ្យ

in order that = ដើម្បី

in order that......not = ដើម្បីកុំឱ្យ

fear (n) = ការភ័យខ្លាច, ការបារម្ភ

for fear of sth = ដោយសារតែការភ័យខ្លាចអំពីអ្វី១

for fear that-clause = ដោយសារតែការភ័យខ្លាចថា.......

for fear that = ដោយសារតែការភ័យខ្លាចឬការបារម្ភ

Love not sleep, *lest* you come to poverty.

ការស្រលាញ់/ស្នេហាមិនបាត់បង់ទេដើម្បីកុំឱ្យអ្នកធ្លាក់ទៅក្នុងភាពក្រីក្រ/ខ្វះសេចក្តីស្រលាញ់។

Do not be idle, *lest* you come to want.

www.salarean.com

កុំខ្ជិលដើម្បីកុំឱ្យអ្នកធ្លាក់ទៅក្នុងភាពក្រីក្រ ។

to come to want = to come to poverty = ធ្លាក់ចូលទៅក្នុងភាពក្រីក្រ

want (n) = poverty

He fled *lest* he *should* be killed. [ ជាទូទៅ lest ប្រើជាមួយ should ]

គាត់រត់គេចខ្លួនដើម្បីកុំឱ្យគេសំលាប់ ។

He fled *in order that* he should not be killed.

I was alarmed lest (=for fear that) we should be wrecked.

| | | | |
|---|---|---|---|
| ខ្ញុំមាន | (ការ)ខ្វាយខ្វល់<br>(ការ)ភ័យខ្លាច<br>ខ្លាច | ក្រែងលោ<br>ដើម្បីកុំឱ្យ | ពួកយើងត្រូវគេកំទេច ។ |

alarmed (adj) = ខ្វល់ខ្វាយ, ខ្លាច

wreck = destiny = កំទេច, បំផ្លាញ

for fear that = ក្រែងលោ

(Note: *Lest* is more in modern English.)

(សំគាល់: *Lest* គឺកម្រមានណាស់នៅក្នុងភាសាអង់គ្លេសសម័យទំនើប ។)

*** Lest (Adverb of purpoer) នេះនៅក្នុងការប្រើប្រាស់រាល់ថ្ងៃមិនសូវជួបទេ ។ So that ក៏កម្រដែរ ។ ព្រោះ Adverb of purpose នៅក្នុងភាសាអង់គ្លេសសម័យទំនើបគឺជំនួសដោយ Infinitive បដិសេធដែរ ។ ដូចជា to prevent, to avoid គេប្រើជំនួស Lest ។

e.g. I came here so that I can learn English.

I came here to learn English.

Note—The modern idiomatic construction after *lest* is *should*.

ចំណាំ-សំណង់ឃ្លាសំនួនវោហារស័ព្ទសម័យទំនើបក្រោយពាក្យ lest គឺ should ។

After certain expressions denoting *fear* or *apprehension*, *lest* was used as equivalent to *that*; as,

ក្រោយសំនួនវោហារស័ព្ទខ្លះដែលសំគាល់អំពីការភ័យខ្លាច Lest ត្រូវបានគេប្រើជាសមមូលទៅនិងពាក្យ that ដូចជា

I feared *lest* I might anger thee. [ ច្រើនប្រើក្នុងកំណាព្យនិងសៀវភៅរឿង ]

(=I feared *that* I....)

ខ្ញុំខ្លាចក្រែងលោខ្ញុំធ្វើឱ្យខឹង ។

thee = you

to anger (Vt) = ធ្វើឱ្យខឹង

413. *While* is used to mean—

www.salarean.com

413. *While* ត្រូវគេប្រើក្នុងន័យ-

(1) During the time that, as long as; as,

(1) នៅក្នុងអំឡុងពេលដែល, ដរាបណា, ដូចជា

While = នៅពេលដែល

*While* he was sleeping, an enermy sowed tares.

ពេលគាត់កំពុងដេកលក់ សត្រូវរបស់គាត់មកដាំ/សាបព្រោះដើម្ប Tares ។

to sow = សាបព្រោះ

tare = ឈ្មោះដើមឈើម្យ៉ាង

*While* there is life is hope. (Proverb)

ឱ្យតែ/ដរាបណា នៅមានជីវិតនៅមានសង្ឃឹម ។

(2) At the same time that; as,

(2) ទន្ទឹមពេលដែលថា ដូចជា

| At the same time<br>Meanwhile | (Adv) = ទន្ទឹមពេលគ្នានេះដែរ |
|---|---|

While = at the same time that = ទន្ទឹមពេលដែលថា

While (1) = នៅពេលដែល

(2) = ទន្ទឹមពេលដែលថា (នៅពេលដែល)

The gilrs *sang* while the boys played.

ក្មេងស្រីច្រៀងទន្ទឹមពេលដែលក្មេងប្រុសសំដែង ។

While the *boys* played, the gilrs *sang*.

ទន្ទឹមពេលដែលក្មេងប្រុសលេងក្មេងស្រីច្រៀង ។

| | |
|---|---|
| Past Simple + *while* + Past Simple<br>*While* + Past Simple + Past Simple<br>(បញ្ជាក់ពីអំពើព្រមគ្នា) | Sequence of time |
| While + Past Continuous + Past Simple<br>(អំពើមួយកំពុងកើតឡើងមានអំពើមួយទៀតមកកាត់ផ្តាច់) | |

e.g. *While* I *was explaining*, the light *went out*. នៅពេលដែលខ្ញុំពន្យល់ភ្លើងដាច់ ។

The light *went out* (Mian Clause) *while* I was explaining.

*While* he found fault, he also praised.

ទន្ទឹមពេលដែលថាគាត់ចាប់កំហុសគាត់ក៏លើកសរសើរដែរ ។

to find fault = ចាប់កំហុស

to praise = លើកសរសើរ

to find fault (with sb) = ចាប់កំហុស/រកកំហុស (sb)

www.salarean.com

(3) Whereas; as,

(3) ចំណែកឯ/ឯ

While (conj.) = (1) នៅពេលដែល (ដរាបណា)

(2) នៅពេលដែល, ទន្ទឹមពេលដែលថា

(3) (ចំណែក) ឯ [ បង្ហាញពីន័យផ្ទុយគ្នា ]

*While* I have no money to spend, you have nothing to spend on.

នៅពេលដែលខ្ញុំអត់លុយចាយ អ្នកក៏មិនដឹងចាយលុយទៅលើអ្វីដែរ ។

នៅពេលដែលខ្ញុំអត់លុយចាយ អ្នកអត់មានលុយត្រូវចំណាយទៅលើវា ។

*While* this is true of some, it is not true of all.

| | | |
|---|---|---|
| នៅពេលដែលនេះវាជាការពិត | ចំពោះពួកគេ<br>សំរាប់មនុស្សមួយចំនួននោះ | វាមិនមែនជាការពិតសំរាប់មនុស្សទាំងអស់នោះទេ ។ |

true of | some / somebody / sth

414. *Only*, as a Conjunction, means *except that*, but, where it not (that); as,

414. *Only* ជា Conjunction មានន័យថា *លើកលែងតែថា, ប៉ុន្តែ, បើកុំតែ(ថា)* ដូចជា

I would come only I busy. កុំអីខ្ញុំមកហើយទាស់តែរវល់ ។

except that = លើកលែងតែថា......

were it not that = បើកុំតែ(ថា)

(~~If~~) it *were*......

*Were* it......

*** កាលណាលុប If ត្រូវត្រឡប់ Subject មកក្រោយវិញ ។

(~~If~~) I were king.

Were I king.

(~~If~~) it | was / were | not | for + noun / that - clause | = បើកុំតែ

=> | Were | it | not | was / were | . [ ការត្រឡប់បែបនេះគេហៅថា Inversion ]

Only = [ភាសានិយាយ] ទាស់តែ, បើកុំតែ

I would come only I am busy.

កុំអីខ្ញុំមកហើយ *ទាស់តែ/បើកុំតែ* រវល់ ។

A way pretty woman, *only* she squints a little.

កុំអីស្អាតមែនទែនទាស់តែស្រលៀងបន្តិច ។/ ជានារីម្នាក់ស្អាតមែនទែនទាស់តែស្រលៀងភ្នែកបន្តិច ។

www.salarean.com

squint = ស្រលៀងភ្នែក, ស្រឡេវភ្នែក

The day is pleasant, *only* rather cold.

ធាតុអាកាសថ្ងៃនេះគួរជាទីរីករាយទាស់តែត្រជាក់បន្តិច ។

Pleasant = គួរជាទីរីករាយ

He does well, *only* that he is nervous at the start.

គាត់ធ្វើបានល្អទាស់តែគាត់មានអារម្មណ៍ខ្វល់ខ្វាយបន្តិចនៅពេលចាប់ផ្តើមដំបូង ។

nervous = មានអារម្មណ៍ភ័យផងអផង, ដែលខ្វាយខ្វល់, ជ្រួលច្របល់ក្នុងចិត្ត

at the start = នៅពេលចាប់ផ្តើម

I would go with you, *only* I have no money.

កុំអីខ្ញុំទៅជាមួយអ្នកឯងបាត់ហើយទាស់តែអត់លុយ ។

415. *Except* was once in good use as a Conjunction; as,

415. *Except* ធ្លាប់ត្រូវបានគេប្រើប្រាស់យ៉ាងច្រើនជា Conjunction ដូចជា

to be in use = ត្រូវគេប្រើប្រាស់

to be in *good* use = ត្រូវគេប្រើប្រាស់*យ៉ាងច្រើន*

Except (=unless) ye repent, ye shall all likewise perish.

លុះណាតែមានការសោកស្តាយបើមិនអញ្ចឹងទេអ្នកនឹងស្លាប់ក្នុងរបៀបដូចគ្នាទាំងអស់អញ្ចឹង ។

ye = you

to repent = សោកស្តាយចំពោះអ្វី១ដែលបានធ្វើខុស

likewise (adv) = ដូចគ្នាអញ្ចឹងដែរ, (តាមរបៀប)ដូចគ្នា

to perish = be killed = ស្លាប់

unless = លុះណាតែ

*Except* a man be born again, he cannot see the kingdom of God.

លើកលែងតែមនុស្សកើតម្តងទៀតបើមិនអញ្ចឹងទេមិនអាចមើលឃើញអាណាចក្ររបស់ព្រះទេ ។

In modern English, its place has been taken by *unless*.

នៅក្នុងភាសាអង់គ្លេសសម័យទំនើប Except នេះត្រូវបានគេជំនួសដោយ Unless ។

to take {the place of sb / sb's place} = ជំនួស

to take place = កើតឡើង

416. *Without*—The use of *without* as a Conjunction meaning *unless* is now bad English; as,

416. *Without*—ការប្រើ without ជា Conjunction មានន័យថា unless ឥឡូវនេះគឺជាភាសាអង់គ្លេសមិនល្អទេ ដូចជា

I shall not go $\underbrace{\text{without}}_{=unless}$ you do. ខ្ញុំនឹងមិនទៅទេទាល់តែអ្នកទៅ ។

417. *Because, for, since*.—Of these three conjunctions, *because* denotes the closed causual conjunction, *for* the weakest, *since* comes between the two.

www.salarean.com

417. *Because, for, since*(=ដោយសារ).— ក្នុងចំណោម Conjunction ទាំងបីនេះ because វាសំគាល់អំពី Conjunction ដែលប្រាប់ពីមូលហេតុជិតជាងគេ, for មានន័យខ្សោយជាងគេ, ចំណែក since នៅចន្លោះកណ្តាល ។

Denote = សំគាល់

cause (ADJ) conjunction = Conjunction ដែលប្រាប់ពីមូលហេតុ

***** ចំណាំ : One (S) of + plural noun + V......

Of + plural noun , One (S) + V......

e.g. Sok/One (S) of the boys (Prep phrase) is (V) is clever. ក្មេងប្រុសម្នាក់ក្នុងចំណោមក្មេងទាំងអស់គឺឆ្លាត់/ឈ្លាសវៃ ។

Of the boys , one / Sok is clever.

ក្នុងចំណោមក្មេងទាំងអស់នោះមានម្នាក់ឆ្លាតជាងគេ / ក្នុងចំណោមក្មេងទាំងអស់សុកពូកែ ។

www.salarean.com